ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៦៨

ចុះថ្ងៃទី២៥ខែកុម្ភៈឆ្នាំ១៩៩៨

សាលដីកា

លេខ : ៣៤

ចុះថ្ងៃទី២៥ខែកុម្ភៈឆ្នាំ១៩៩៩

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ ៖

| | | | |
|---|---|---|---|
| ១_ | ឯកឧត្តម | ឌិត មុន្ទី | ជាប្រធាន |
| ២_ | លោក | ប៉ែន ស៊ុន | ជាចៅក្រម |
| ៣_ | លោក | រៀល មួន | ជាចៅក្រម |
| ៤_ | លោក | ស៊ិន ឌឹម | ជាចៅក្រម_របាយការណ៍ |
| ៥_ | លោក | ជីវ កេង | ជាចៅក្រម |
| | | ក្រឡាបញ្ជី | |
| | លោក | សុង ម៉ៅ | |
| | | តំណាងមហាអយ្យការ | |
| | លោក | សាយ សារី | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខពីសាលដីកាលេខ៧៦៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៨៦ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្ដឹងសាទុក្ខឈ្មោះសៅ ម៉ន ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ របរ នាយកវិទ្យាល័យ១ឧសភា ទីលំនៅសព្វថ្ងៃភូមិព្រៃឈើទាលក្រោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ឪពុកឈ្មោះសៅ ម៉ឹង "ស" ម្ដាយឈ្មោះអ៊ុក មុត "រ" ប្រពន្ធឈ្មោះសាំង សារីម មានកូន៤នាក់ ។

និងចុងបណ្ដឹងសាទុក្ខឈ្មោះអ៊ុយ នាវ ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ របរធ្វើស្រែ ទីលំនៅភូមិខ្នាគ្រហឹម ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ។ ឪពុកឈ្មោះអ៊ុយ បិទ "ស" ម្ដាយឈ្មោះម៉ុត អ៊ឹម "ស" ប្រពន្ធឈ្មោះថោង សំណាង មានកូន១១នាក់ ។

<u>កម្មវត្ថុ</u> ប្ដឹងទាមទារសាលារៀនរក្សាជាសម្បត្តិសាធារណៈនិងសុំឱ្យចុងចម្លើយរុះរើផ្ទះចេញពីដីទំនាស់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ២១ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨របស់ឈ្មោះសៅ_ម៉ន ប្ដឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលា_

mou

ឧទ្ធរណ៍លើសាលដីកាទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៦៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៤_០១_៩៦ របស់ឈ្មោះសៅ ម៉ន ប្តឹងពីឈ្មោះអ៊ុយ នារ ទាមទារដីសាលារៀនមករក្សាទុកជាសម្បត្តិសាធារណៈ ដោយហេតុថា១៩៨១ឈ្មោះអ៊ុយ នាង បានសុំអនុញ្ញាតពីលោកអ៊ីវ សារិត នាយកសាលាដើម្បីស្នាក់នៅជាបណ្តោះអាសន្នសិនទំរាំរកជំរកស្នាក់នៅបាន។ ពេលលោក អ៊ីវ សារិត និងរដ្ឋអំណាចបានរកផ្ទះនិងដីឱ្យគាត់នៅ ប៉ុន្តែឈ្មោះអ៊ុយ នារ នៅតែមិនព្រមចេញពីដីនេះរហូតដល់សព្វថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ០១ "ខ" ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៧ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១_ ទទួលពាក្យបណ្តឹងចុះថ្ងៃទី៤_០១_៩៦របស់លោកសៅ ម៉ន "ដើមចោទ" ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២_ បដិសេធបណ្តឹងតបចុះថ្ងៃទី៥_២_៩៦របស់លោកអ៊ុយ នារ "ចុងចម្លើយ" ចោលជាអសារបង់ ។

៣_ ដីដែលមានទំហំ៧២៥៤២ម៉ែត្រការ៉េមានព្រំប្រទល់ខាងជើងទល់ផ្លូវចូលវត្ត ខាង_ត្បូងទល់ទំនប់ទឹក ខាងកើតទល់ដីឈ្មោះគង់ ហង់_ ទូច រឿន _ញែម រ៉ាន_ទូច ជុំន អ៊ុយ ម៉ុចអ៊ុយ សឿន _ផង អ៊ុន_ អ៊ុយ សេង_និងឈ្មោះណុប សុផល និងខាងលិចទល់ដីឈ្មោះកែវ_អានស្រី ឆែម_ទូច រឿន_ ឡុង សារុននិងឈ្មោះអៀង ច្រិប ។ ស្ថិតនៅភូមិខ្នាគ្រហឹម ឃុំតាភេមស្រុកត្រាំកក់ ខេត្តតាកែវ ត្រូវរក្សាទុកជាដីរបស់សាលារៀនវិទ្យាល័យ១ឧសភា ខ្នាគ្រហឹម ស្រុកត្រាំកក់ខេត្តតាកែវ ។

៤_ បង្គាប់ឱ្យចុងចម្លើយឈ្មោះអ៊ុយ នារ "ចុងចម្លើយរុះរើលំនៅដ្ឋានចេញពីដីទំនាស់នេះក្នុងកំណត់រយៈពេលមួយខែ គិតចាប់តាំងពីថ្ងៃផុតកំណត់ប្តឹងឧទ្ធរណ៍ ។

៥_ បង្គាប់ឱ្យឈ្មោះអ៊ុយ នារ ចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ៊្វីង១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល ចំណាយលើអ្នកប្រគល់ដីកាកោះ៥.០០០រៀលសរុប៧.០០០រៀល ប្រាក់នេះត្រូវបានដកពីប្រាក់៧.០០០រៀល ដែលដើមចោទបានបង់ទុករួច ។

កាលបើផុតកំណត់ឧទ្ធរណ៍បង្គាប់ឱ្យចុងចម្លើយឈ្មោះអ៊ុយ នារ សងប្រាក់៧.០០០រៀល នេះឱ្យទៅដើមចោទវិញ ។

៦_ បង្គាប់ឱ្យចុងចម្លើយឈ្មោះអ៊ុយ នារ បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំនាស់គឺ $\frac{៤០.៥០០.០០០\times១}{១០០}$ = ៤០៥.០០០រ(ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ៨០ភាគរយគឺ $\frac{៤០៥.០០០\times៨០}{១០០}$ =

៣២៨.៤០០រៀល និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយគឺ៤០៥.០០០×២០ = ៨១.០០០រៀល
១០០

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវឧទ្ធរណ៍កំណត់៦០ថ្ងៃគិតចាប់តាំងពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ របស់ឈ្មោះអ៊ុយ នាវ មិនសុខចិត្តនិងសាលក្រមរដ្ឋប្បវេណីលេខ០១ "ខ" ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៧ របស់តុលាការខេត្តតាកែវត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៧របស់សលាឧទ្ធរណ៍នៃសេចក្តីសំរេចដូចតទៅ ៖

១_ ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០_១_៩៧ របស់ឈ្មោះអ៊ុយ នាវ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២_ បដិសេធសាលក្រមលេខ០១"ខ"ចុះថ្ងៃទី៦_១_៩៧ របស់តុលាការខេត្តតាកែវចោលជាអសារបង់ ។

៣_ ប្រគល់ ផ្ទះទំនាស់ដែលស្ថិតនៅលើដីទំនាស់ABEFទទឹង[AB] [FE]=35m បណ្តោយ [AF]=[BE] ទល់នឹងចំការស្វាយចន្ទីដែលស្ថិតក្នុងប្រវែង៤ម៉ែត្រ ចាប់ពីផ្ទះទំនាស់និងទីចាត់ការឱ្យទៅអ៊ុយ នាវ កាន់កាប់ជាកម្មសិទ្ធិចាប់ពីសាលដីកានេះចូលជាស្ថាពរ ។

៤_ ដីនិងផ្ទេរ(ទីចាត់ការ)ដែលនៅសល់ក្រៅពីនេះប្រគល់ឱ្យសាលារៀន(មើលផែនទីបង្ហាញទីតាំងដីទំនាស់ចុះថ្ងៃទី១២_២_៩៦ របស់ការិយាល័យភូមិបាលស្រុកត្រាំកក់ និងបំណុចបង្កើតឡើងដោយសាលាឧទ្ធរណ៍នៅលើគំនូសប្លង់នោះ) ។

៥_ កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រុពន្ធចុះបញ្ជីក្តីនិងពន្ធហ្វឹង២.៥៥០រ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រចំណាយលើដីកាកោះ៥.០០០រ អាជ្ញាធរតុលាការ៥.០០០រ ។

៦_ សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២១ ចុះថ្ងៃទី២២_០១_៩៨របស់លោកសៅ ម៉ន ស្ថិតក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពាររបស់ឈ្មោះសៅ ម៉ន ចុះថ្ងៃទី៤_ខែមេសា ឆ្នាំ១៩៩៨។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះអ៊ុយ នាវ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៨។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖

សាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣_១២_៩៧ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ និង គតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសៅ ម៉ន ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយថាៈ ដីជារបស់រដ្ឋមិនត្រូវមានមនុស្សណាមកនៅទេ ក្នុងភូមិរដ្ឋអំណាចភូមិរកដីឱ្យហើយ សាលាឧទ្ធរណ៍សំរេចឱ្យដីទៅគាត់មិនមែនទេដីប្រធានភូមិឱ្យមួយនាក់១០១A ដីនេះគាត់កំពុងកាន់កាប់ ហើយឱ្យផ្ទះទៀតផងតាំងឆ្នាំ៨២ ហើយផ្ទះនេះចៅហ្វាយស្រុកយកបាត់ហើយដីប្ដូនកន្លែង១កន្លែងជារបស់គាត់ចាស់ គាត់មិនយកដីទាំងនេះ គេយកអស់ហើយ ។ បើគាត់ទៅនៅកន្លែងឯណារដ្ឋអំណាចរកឱ្យ ។ ខ្ញុំជានាយកពីឆ្នាំ៩២មកទេ សាលាខ្នាត្រហឹមនេះបង្កើតតាំងពីឆ្នាំ៨១មក ផ្ទះដែលថាឱ្យគាត់ គាត់យកមិនទាន់គេនោះតាមពិតគាត់មិនយក ។ សាលានោះគ្មានរបងអ្វីត្រឹមត្រូវទេ តែមានភូមិបាល កំណត់ត្រឹមត្រូវ ។ ខ្នាត្រហឹមមានឈ្មោះជាសាលា៧៩រដ្ឋអំណាចប្រគល់ឱ្យឆ្នាំ៨០ឆ្នាំ៨០គាត់ធ្វើជាមេឃុំ ។

បានស្តាប់ចម្លើយរបស់ឈ្មោះអ៊ុយ នាវ ជាចុងចម្លើយបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថាៈ ខ្ញុំចាំបានខ្លះដីប្ដូនកន្លែងសៅ ម៉ន ថាខ្ញុំមិនដែលស្គាល់ទេ គាត់មិនដែលជាន់ដីខ្ញុំទេ សូម្បីព្រំប្រទល់និងទំហំគាត់មិនដឹងផង ខ្ញុំនិងគាត់មិនដែលទាក់ទងគ្នានិយាយរឿងដីធ្លីនេះទេ ដូចជាផ្ទះជាដើមគេមិនឱ្យខ្ញុំទេសូម្បីដីប្រធានភូមិមិនឱ្យផង ក្រោយមកដោយមានអន្តរាគមន៍ពីចៅហ្វាយស្រុកផង គេឱ្យផ្ទះខ្ញុំតែផ្ទះនោះគេនៅរួចទៅហើយ ខ្ញុំក៏នៅកន្លែងដើមវិញ ឯផ្ទះនោះគេថាឱ្យខ្ញុំនោះសុទ្ធតែគេនៅអស់ទៅហើយតាំងពីពេលនោះមក ។ ឆ្នាំ៧៩និង៨០_៨១នណានៅត្រង់ណាក៏បានដែរ គេនៅរហូតដល់សព្វថ្ងៃនោះក្លាយជាកម្មសិទ្ធិរបស់គេរួចទៅហើយ តែខ្ញុំកម្មអ្វី បែរជាចង់ឱ្យខ្ញុំចេញពីដីនេះទេវិញ តើឱ្យខ្ញុំចេញទៅនៅឯណា ។ សេចក្តីសន្និដ្ឋានរបស់មេធាវីចុងបណ្តឹងសាទុក្ខ ៖ សាលារៀននេះមិនមែនជាសាលារៀនសោះ ព្រោះជាអាគារបាក់បែកមែនគាត់អ៊ុយ_នាវ រស់នៅតាំងពីឆ្នាំ៨១មកឆ្នាំ៩១បែរជាមកព័ទ្ធយកដីទាំងដីស្រែគាត់ធ្វើតាំងពីឆ្នាំ៧៩មកផង តាមអនុក្រឹត្យលេខ២៥អនក្រ និងច្បាប់ភូមិបាល សូមឱ្យរដ្ឋធ្វើជាគោលនយោបាយឱ្យគាត់ បើសិនណាឱ្យគាត់ចេញសូមទុកដីស្រែឱ្យគាត់ ។

អ៊ុយ នាវ ៖ សូមឯកឧត្តមមេត្តា ចែករំលែកដីឱ្យខ្ញុំបាននៅផងខ្ញុំមិនទាស់ទេ បើយកដីនេះធ្វើសាលាធ្វើនោះ តែបើយកទៅលក់ខ្ញុំសុំសិទ្ធិជំទាស់ កន្លងមកគេយកដីស្រែរបស់សាលាទៅដាំស្វាយចន្ទីសំរាប់ជាប្រយោជន៍របស់ខ្លួនទេវិញ ដីស្រែខ្ញុំបានធ្វើកន្លងមកខ្ញុំសូមធ្វើដដែលវិញឆ្នាំ៨១ពេលខ្ញុំចូលនៅដីគ្មានសាលាទេ ជាកន្លែងកប់ខ្មោចទៀតផង គ្មានសិស្ស គ្មានគ្រូទេ បើសៅ ម៉ន ថាឆ្នាំ៨១_៨២_៨៣ ៨៤ ថាកន្លែងនោះមានសាលារកគ្រូមកបង្ហាញទៅ នៅឆ្នាំ៨៤ទើបរំលែកសិស្សពីសាលា១ឧសភាមកកាន់

កន្លែងនេះ ខ្ញុំនៅសព្វថ្ងៃជាអាគារចាស់របស់ប៉ុលពតមិនមែនសាលាទេ ខ្ញុំនៅសព្វថ្ងៃក៏ដើម្បីរក្សាការពារអាគារដែរ ។

ខ្ញុំបដិសេធពាក្យរបស់សៅ ម៉ន ថាគ្រូគេចេញអស់ហើយ នៅតែខ្ញុំតាមពិតគ្រូៗមកនៅនោះគេមិនមកនៅកន្លែងខ្ញុំ នៅនេះទេ គេនៅសាលា១ឧសភា ឯណោះ ឃ្លាតពីគ្នា៦០០ទៅ៧០០ម៉ែត្រ ។

ខ្ញុំសន្យាថា បើយកដីនេះធ្វើសាលាសូមធ្វើចុះ តែខ្ញុំសូមចំណែកដីផងលើដីនោះខ្ញុំដាំដូង ខ្នុរ ចេក ហើយឱ្យខ្ញុំចេញទៅណា ?

ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .

ក្រោយពីបានស្ដាប់ចម្លើយដោះសារ របស់គូភាគី និងសេចក្ដីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ .

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

### តុលាការកំពូល

_ យល់ឃើញថា បណ្ដឹងសាទុក្ខលេខ២១ ចុះថ្ងៃទី២២_០១_៩៨ របស់លោកសៅ ម៉ន ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

_ យល់ឃើញថាៈមានភស្ដុតាងគ្រប់គ្រាន់បញ្ជាក់ថា ចុងចម្លើយពិតជាបានទិញដីសាលារៀនស្នាក់នៅបណ្ដោះអាសន្នពិតប្រាកដមែន ។

_ យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់ឱ្យទៅចុងចម្លើយជាការភ័ន្តច្រឡំ ពីព្រោះថាៈ ទីតាំងផ្ទះ និងដីទំនាស់របស់ចុងចម្លើយស្ថិតនៅក្នុងបរិវេណសាលារៀនដែលជាដីសាធារណៈ ហើយ ដែលតាមមាត្រា៥នៃច្បាប់ភូមិបាល និងមាត្រា៦នៃអនុក្រឹត្យលេខ២៥អនក្រ ចុងចម្លើយពុំអាចមានសិទ្ធិជាកម្មសិទ្ធិលើដីនិងអាគារនេះបានឡើយ ។

_ យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣_១២_៩៧ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្ដីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្ដី ចំពោះមុខគូក្ដី

១_ ទទួលបណ្ដឹងសាទុក្ខលេខ២១ ចុះថ្ងៃទី២២_០១_៩៨របស់លោកសៅ ម៉ន ទុកជាត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧៦៩ ចុះថ្ងៃទី២៣_១២_៩៧ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៦៨ ចុះថ្ងៃទី២៥_០៧_៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកសៅ ម៉ន បានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០៛ គឺ

_ ពន្ធចុះបញ្ជីក្តី និងពន្ធហ្មឺងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

_ ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

ហើយតម្រូវឱ្យលោកអ៊ុយ នាវ សងប្រាក់ចំនួន១៩.០០០៛ នេះទៅលោកសៅ ម៉ន វិញ ។

៥_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។